ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ១០/៦៦៦ សនលា.អគ.មរជ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រីជាគ្រួសារក្រីក្រ និងសេវាករអគ្គិសនីនៅតំបន់ជនបទក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា៖ នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា (បន្ទាប់ពីនេះទៅហៅថា "ម.អ.ជ.") មាន "កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ"។ គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្រនៅតំបន់ជនបទ អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយផ្តល់ប្រាក់កម្ចីគ្មានការប្រាក់យកទៅ៖ ១- បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២- បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣- ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង៤- ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី 480,000រៀល ក្នុង១គ្រួសារ។ ប្រាក់កម្ចីនេះនឹងទូទាត់តាមរយៈអ្នកផ្គត់ផ្គង់អគ្គិសនី ដែលជាអ្នកទទួលខុសត្រូវចំពោះ ម.អ.ជ. ក្នុងការប្រមូលពីអ្នកខ្ចីដែលត្រូវសងរំលស់ ១ខែម្តងមក ម.អ.ជ. ក្នុងរយៈពេល ៣៦ខែ។

កម្មវិធីនេះ ជាកម្មវិធីអនុវត្តន៍បន្តពីឆ្នាំ២០១៣ និងនៅបន្តអនុវត្តក្នុងឆ្នាំ២០១៥។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក គឹម ឫទ្ធី ទូរស័ព្ទលេខ 089 267-071 ឬ លោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. ទូរស័ព្ទលេខ 023 997-600 ឬទូរសារលេខ 023 997-601 ឬ អញ្ជើញមកទំនាក់ទំនងនៅការិយាល័យ ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

<u>ចម្លងជូន៖</u>
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ